**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ថ្ងៃ ចន្ទ ៨រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ២០២៤

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ផែនការបោះផ្សាយលក់មូលបត្ររដ្ឋឆ្នាំ២០២៥

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមជូនដំណឹងដល់វិនិយោគិនសក្តានុពលទាំងអស់ជ្រាបថា អនុលោមតាមច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ និងក្របខ័ណ្ឌគោលនយោបាយស្តីពីការអភិវឌ្ឍមូលបត្ររដ្ឋ ២០២៣-២០២៨ របស់រាជរដ្ឋាភិបាល, សម្រាប់ឆ្នាំ២០២៥នេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការបោះផ្សាយលក់មូលបត្ររដ្ឋ តាមរយៈការដេញថ្លៃនៅលើថ្នាលរបស់ធនាគារជាតិនៃកម្ពុជា (National Bank of Cambodia Platform - NBCP) ក្នុងទំហំ **៥០០ ០០០ ០០០ ០០០** (ប្រាំរយប៊ីលាន) រៀល ដូចមានព័ត៌មានលម្អិតខាងក្រោម៖

**ក) តម្លៃចារឹកក្នុងមួយប័ណ្ណ៖** ១ ០០០ ០០០ (មួយលាន) រៀល

**ខ) ប្រភេទមូលបត្រ៖** ឥណប្រតិទាន ១ឆ្នាំ, ២ឆ្នាំ, ៣ឆ្នាំ, ៥ឆ្នាំ, ១០ឆ្នាំ, និង ១៥ឆ្នាំ

**គ) ប្រភេទអត្រាគូប៉ុង៖** ថេរ

**ឃ) ការទូទាត់គូប៉ុង៖** រៀងរាល់ ៦ ខែម្តង ដោយគិតចាប់ពីថ្ងៃបោះផ្សាយ

**ង) មូលដ្ឋានរាប់ថ្ងៃ៖** Actual/Actual

**ច) ការសងប្រាក់ដើម៖** ទូទាត់សងនៅចុងឥណប្រតិទាន

**ឆ) វិធីសាស្ត្រដេញថ្លៃ និងចំនួនស្នើដេញថ្លៃ៖** Multiple Price Auction & Multiple Bids

**ជ) គម្លាតនៃការបោះផ្សាយ៖** ៤ សប្តាហ៍ម្តង

**ឈ) ទំហំគ្រោងបោះផ្សាយ (Indicative Amount)៖**

| ប្រភេទមូលបត្រ | ចំនួនដងនៃការបោះផ្សាយ | ទំហំគ្រោងបោះផ្សាយ (ប៊ីលានរៀល) |
|---|---|---|
| ឥណប្រតិទាន ១ឆ្នាំ | ២ | ១៦០ - ២០០ |
| ឥណប្រតិទាន ២ឆ្នាំ | ២ | ១៥០ - ១៩០ |
| ឥណប្រតិទាន ៣ឆ្នាំ | ២ | ១៤០ - ១៨០ |
| ឥណប្រតិទាន ៥ឆ្នាំ | ២ | ២០ - ៤០ |
| ឥណប្រតិទាន ១០ឆ្នាំ | ២ | ២០ - ៤០ |
| ឥណប្រតិទាន ១៥ឆ្នាំ | ២ | ១០ - ៣០ |


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

៣) កាលវិភាគបោះផ្សាយ៖

| កាលបរិច្ឆេទ | ប្រភេទឥណប្រតិទាន | | | | | |
|---|---|---|---|---|---|---|
| | ១ឆ្នាំ | ២ឆ្នាំ | ៣ឆ្នាំ | ៥ឆ្នាំ | ១០ឆ្នាំ | ១៥ឆ្នាំ |
| ២២ មករា | ✓ | | | | | |
| ១៩ កុម្ភៈ | | ✓ | | | | |
| ១៩ មីនា | | | ✓ | | | |
| ២៣ មេសា | ✓ | | | | | |
| ២១ ឧសភា | | ✓ | | | | |
| ២៥ មិថុនា | | | ✓ | | | |
| ២៣ កក្កដា | | | | ✓ | | |
| ២០ សីហា | | | | | ✓ | |
| ១៧ កញ្ញា | | | | | | ✓ |
| ២២ តុលា | | | | ✓ | | |
| ១៩ វិច្ឆិកា | | | | | ✓ | |
| ១០ ធ្នូ | | | | | | ✓ |

សេចក្តីជូនដំណឹងលម្អិតស្តីពីការបោះផ្សាយលក់មូលបត្ររដ្ឋមួយលើកៗ និងលទ្ធផលស្តីពីការដេញថ្លៃមូលបត្ររដ្ឋ នឹងមានផ្សព្វផ្សាយលើបណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា។

*© ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រក្សាសិទ្ធិក្នុងការកែសម្រួលផែនការបោះផ្សាយនេះ តាមការចាំបាច់។*